# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា

*********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញសេចក្តីសំរេចលេខ ៤២ ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានអក្សរកាត់ថា " អ ជ ទ ក " ។

**មាត្រា២ .-**

អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានសមាសភាពដូចតទៅ :

១-ឯកឧត្តម ទេីង សឹីវុឌ្ឍ ទេសរដ្ឋមន្ត្រី ប្រធាន

២-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ា សឺីវុឌ្ឍ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អនុប្រធាន

| | | |
|---|---|---|
| ៣-ឯកឧត្តម **ឡាយ ព្រហ្មស្ម** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤-ឯកឧត្តម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥-ឯកឧត្តម **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិកប្រចាំការ |
| ៦-ឯកឧត្តម **ព្រំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨-ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០-ឯកឧត្តម **ចំន្ទ គុងអ៊ីវ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១-ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២-ឯកឧត្តម **នឹម ថូត** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៣-ឯកឧត្តម **ថាច់ ខែន** | រដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ១៤-ឯកឧត្តម **ពេជ្រ សោភ័ណ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ១៥-ឯកឧត្តម **ម៉ុន ណារិទ្ធ** | ប្រធានអគ្គនាយក អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា | សមាជិក |
| ១៦-ឯកឧត្តម **សយ សុខាន់** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៧-លោកឧត្តមសេនីយ៍ **យុន ឈុន្លី** | ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៨-អគ្គលេខាធិការ " អជទក " | | សមាជិក |

**មាត្រា៣ ._**

អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម :

-ជួយរាជរដ្ឋាភិបាល ក្នុងការរៀបចំកសាងគោលនយោបាយ យុទ្ធសាស្ត្រជាតិ ផែនការអភិវឌ្ឍន៍ ការត្រួតពិនិត្យ និងសម្របសម្រួលការងារអនុវត្ត លើការអភិវឌ្ឍវិស័យឧស្សាហកម្មទេសចរណ៍ជាតិ

-ត្រៀមការងារជូនរាជរដ្ឋាភិបាល ដើម្បីសំរេចលើគំរោងអភិវឌ្ឍន៍ ឬវិនិយោគនានា នៃវិស័យឧស្សាហកម្មទេសចរណ៍

-ណែនាំក្រសួងទេសចរណ៍ក្នុងការតាមដាន បញ្ជាក់ និងឆ្លុះបញ្ចាំងលទ្ធផល នៃការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ ព្រមទាំងផែនការសកម្មភាពទាំងឡាយដែលទាក់ទងដល់កិច្ចអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍

-កំណត់គោលដៅអាទិភាព សំរាប់កិច្ចអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍

-ទទួលបន្ទុករៀបចំ និងលើកគំរោងការងារ ផ្សព្វផ្សាយ និងទីផ្សារទេសចរណ៍ រួមទាំងព្រឹត្តការណ៍ទេសចរណ៍

-ទទួលបន្ទុករៀបចំ និងលើកគំរោងការងារសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរណ៍

-សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន និងសមាគមទាំងឡាយដែលប្រកបអាជីវកម្មវិស័យឧស្សាហកម្មទេសចរណ៍ លើការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព ដែលជាប់ទាក់ទងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មទេសចរណ៍ ដោយឈរលើមូលដ្ឋាននៃផែនការអភិវឌ្ឍន៍ជាតិ

-សហការជាមួយអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ក្នុងការលើកគំរោងអភិវឌ្ឍវិស័យទេសចរណ៍នៅតំបន់សៀមរាប អង្គរ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ឱ្យបានទៀងទាត់ ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤ ._**

-អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានអគ្គលេខាធិការដ្ឋានជាជំនួយការ និងមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ដឹកនាំដោយអគ្គលេខាធិការមួយរូប ទទួលបន្ទុកកិច្ចការរដ្ឋបាល ថវិកា និងការរៀបចំគ្រប់គ្រងឯកសារទូទៅ

-អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់

-អគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយក

-ប្រធានផ្នែកជំនាញ មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានមន្ត្រីមួយចំនួនជាជំនួយការ ។

**មាត្រា៥ .-**

អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ត្រូវធ្វើការប្រជុំសាមញ្ញរៀងរាល់មួយត្រីមាសម្តង ហើយអាចកោះប្រជុំជាវិសាមញ្ញតាមការចាំបាច់ និងតាមការអញ្ជើញរបស់ប្រធាន " អ ជ ទ ក " ។ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានសិទ្ធិទទួលមធ្យោបាយសំភារៈទេសចរណ៍ និងប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល គ្រឹះស្ថានឯកជននានា សំរាប់កិច្ចដំណើរការការងាររបស់ខ្លួន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៦ .-**

អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- ឯកសារ-កាលប្បវត្តិ